# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល**

# ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

៣៣៣*៣៣

លេខៈ ៤៩៥

ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា**

**តុលាការកំពូល**

លេខៈ ៥៦

ចុះថ្ងៃទី០៩ ខែ មិនា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខិម មុន្នី** | | ជាប្រធាន |
| ២-លោក | រៀល មួន | | ជាចៅក្រមរបាយការណ៏ |
| ៣-លោក | គង់ ភីរុន | | ជាចៅក្រម |
| ៤-លោក | ប៉ែន សារឿន | | ជាចៅក្រម |
| ៥-លោក | សោម សិរីវឌ្ឍ | | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **សុខ ម៉ៅ**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៧៥ "ច" ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩១ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៏រវាង :

ដើមចោទឈ្មោះ **យី ឆេង** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១១០G ផ្លូវជាតិលេខ៦A សង្កាត់ ព្រែកលៀប ខណ្ឌឫស្សីកែវ ។ ឪពុកឈ្មោះយី យាន (ស) ម្តាយឈ្មោះយុយ សួន (ស) ប្តីឈ្មោះ អុន សេន មានកូន០៣នាក់ ។

មានមេធាវីលោក យិន វេងកា ។

ចុងចម្លើយឈ្មោះ **ចាន់ សានី ហៅ យី គីមអេង** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃ ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

**__កម្មវត្ថុបណ្តឹង__** : ប្តឹងសុំឱ្យចុងចំលើយចុះចេញពីផ្ទះ

បានឃើញបណ្តឹងសាទុក្ខលេខ ៣២២ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០០៣ របស់ឈ្មោះ ចាន់ សានី ហៅ យី គីមអេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៥"ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤៥៥ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៤-១០-២០០២ អ្នកស្រី យី ឆេង ប្តឹងសុំឱ្យឈ្មោះ ចាន់ សានី និងប្រពន្ធចុះចេញពីផ្ទះ និងដីដែលមាននៅក្នុងប័ណ្ណសំគាល់សិទ្ធិលេខ ច.x១០៣២ ចុះថ្ងៃទី២៥-០៧-១៩៩៥ ស្ថិតនៅភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដោយសំអាងហេតុថា ចុងចំលើយទើបតែមកវិលោភចូលមករស់នៅក្នុងឆ្នាំ១៩៩៨ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៧"ង" ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៤-១០-២០០២ របស់អ្នកស្រី យី ឆេង ប្តឹងសុំឱ្យឈ្មោះ យី គីមអេង ហៅចាន់ សានី និងគ្រួសារចាកចេញពីផ្ទះ និងដីរបស់ខ្លួន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ឱ្យឈ្មោះយី គីមអេង ហៅចាន់ សានី និងគ្រួសារចាកចេញពីផ្ទះ និងដីរបស់អ្នកស្រីយីឆេង ស្ថិតនៅផ្ទះលេខ១១០G ផ្លូវ៦A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ តាមបញ្ញត្តិមាត្រា៣៥ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកប/០៨០១/០៤ ចុះថ្ងៃទី៣០-៨-២០០១ ។

៣-ឱ្យឈ្មោះយី គីមអេង ហៅចាន់ សានី បង់ជម្ងឺចិត្តចំនួន១.០០០ $(មួយពាន់ដុល្លារអាមេរិក) ឱ្យឈ្មោះយី ឆេង ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។ សុំលើសពីនេះលើកចោល ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់រួចហើយ ដោយ : បង់ពន្ធបញ្ជើក្តី...

និងពន្ធហ្លឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ចំនួន ៥.០០០៛ សរុប ចំនួន៧.០០០៛ ។ បើសាលក្រមនេះស្ថាពរឱ្យឈ្មោះយី គីមអេង ហៅ ចាន់ សានី សងប្រាក់៧.០០០៛ នេះទៅឈ្មោះ យី ឆេង វិញ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ ។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើកផ្លូវឧទ្ធរណ៍ រយៈពេល០២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣របស់ឈ្មោះយី គីមអេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៧"ង" ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៥"ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-០២-២០០៣ របស់ឈ្មោះ ចាន់ សានី ហៅយី គីមអេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះទាស់នឹងគិតច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ០៧"ង" ចុះថ្ងៃទី០៣-០២-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង ២៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤០០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣២២ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០០៣ របស់ឈ្មោះ ចាន់ សានី ហៅ យី គីមអេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៥"ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះ ចាន់ សានី ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះ យី ឆេង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៧៥ "ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ចាន់ សានី នាពេលជំនុំជំរះថា : នៅសាលាឧទ្ធរណ៍ ខ្លួនបាននិយាយច្រើន កាលពីនៅតុលាការក្រុង គេមិនឱ្យខ្លួននិយាយច្រើនទេ បែរជាសំរេចតែម្តង សាលាឧទ្ធរណ៍សំរេចអយុត្តិធម៌ ព្រោះថា មិនបានហៅសាក្សីមកបំភ្លឺទេ ឯចៅក្រមរបាយការណ៍អានអំបាញ់មិញ គឺខុសការពិតទាំងអស់ ដូចសារណាខ្លួនបានលើកសព្វគ្រប់មកហើយ សូមពិចារណាលើសារណាខ្លួនចុះ និង សំណូមពរពេលនេះ សុំរស់នៅលើផ្ទះនេះបន្តទៀតជាបណ្តោះអាសន្នសិន ទំរាំខ្លួនរកទីលំនៅថ្មីបាន ពេលខ្លួនចុះចេញ សន្យាមិនយកអ្វីទេ ហើយបើច្បាប់អនុវត្តយ៉ាងណាខ្លួនគោរពតាមទាំងអស់ ខ្លួនរស់នៅសព្វថ្ងៃអត់លទ្ធភាពទេ ឯផ្ទះទំនាស់នេះ ខ្លួនទទួលស្គាល់ថា ឪពុកម្តាយខ្លួនបានប្រគល់ឱ្យប្អូនស្រីពៅមែន ។ ចំពោះលិខិតស្នាមផ្សេងៗ ចុងចំលើយបានលួចធ្វើក្លែងបន្លំទាំងអស់ សព្វថ្ងៃខ្លួនមានកូនខ្ទមតូចមួយទុកសំរាប់ជួលប៉ុណ្ណោះ ។

បានស្តាប់ចំលើយរបស់ឈ្មោះ យី ឆេង នាពេលសវនាការថា : ចុងចំលើយនិយាយមួលបង្កាច់ទាំងអស់ គាត់មានវីឡានៅទួលគោក ពេលលែងលះប្រពន្ធដើម គាត់យកប្រពន្ធចុង ហើយមកនៅជាមួយខ្លួន ដោយសារប្រពន្ធចុងនេះហើយ ធ្វើឱ្យម្តាយខ្លួនស្លាប់ ខ្លួនថែទាំម្តាយរហូតដល់គាត់ស្លាប់ ចុងចំលើយមិនដែលអើពើជាមួយម្តាយទេ តែដោយគោរពតាមបណ្តាំម្តាយ ខ្លួនសុខចិត្តអនុវត្តតាមបណ្តាំ តែចុងចម្លើយនៅតែលោភលន់ទាមទារចំណែកផ្ទះខ្លួនទៀត ខ្លួនមិនអាចឱ្យចុងចម្លើយរស់នៅលើផ្ទះខ្លួនបានទេ ព្រោះគាត់បង្ករឿងច្រើនណាស់ ហើយធ្លាប់បានវាយធ្វើបាបខ្លួនទៀតផង សំណូមពរឱ្យចុងចំលើយចុះចេញពីផ្ទះខ្លួន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក យិន វេងកា ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថា : ចុងចម្លើយបានទទួលស្គាល់ហើយនាពេលសវនាការនេះថា ផ្ទះជារបស់អ្នកស្រី យី ឆេង គាត់សុំរស់នៅជាបណ្តោះអាសន្ន ការសុំរបស់ចុងចម្លើយនេះ មិនត្រឹមត្រូវទេ ផ្ទះឯងមានមិននៅ បែរជាមកនៅលើផ្ទះគេ ឯកសារផ្សេងៗធ្វើស្របច្បាប់ទាំងអស់ ។ សំណូមពរ សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ,,

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២២ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៣ របស់លោក ចាន់ សានី ហៅ យី គីមអេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោក ចាន់ សានី លើកឡើងក្នុងសារណា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៣ របស់លោកថា អ្នកស្រី យី ឆេង បានក្លែងបន្លំអក្សរ និងស្នាមមេដៃរបស់លោកនោះ ពុំមានភស្តុតាងណាបញ្ជាក់ដែលអាចឱ្យតុលាការជឿបានឡើយ ។

- យល់ឃើញថា មុនទទួលមរណៈភាព សពលោកយាយយុយ សួន បានបែងចែកមរតករបស់លោកយាយឱ្យកូន និងចៅគ្រប់ៗគ្នា ដាច់ស្រេចអស់ហើយ ហើយផ្ទះនិងដីដែលជាទីតាំងទំនាស់នេះ ត្រូវបានទៅអ្នកស្រីយី ឆេង ដែលបានបំពេញកិច្ចធ្វើប័ណ្ណសំគាល់សិទ្ធិត្រឹមត្រូវតាមច្បាប់ ដោយពុំមានការជំទាស់តវ៉ាពីទាយាទណាឡើយ រួមទាំងលោក ចាន់ សានីផង ដូច្នេះ ការដែលលោក ចាន់ សានី នាំគ្រួសារទៅរស់នៅលើផ្ទះ និងដីរបស់អ្នកដទៃនោះជាការពុំត្រឹមត្រូវទេ ។

- យល់ឃើញថា ការដែលលោកចាន់សានីសំណូមពរស្នាក់នៅបន្តទៀត ទំរាំមានលទ្ធភាពនោះ តុលាការកំពូលពុំមានសមត្ថកិច្ច និងសំរេចបានឡើយ ពីព្រោះដើមចោទមិនយល់ព្រម ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៥"ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣២២ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់លោក ចាន់ សានី ហៅ យី គីមអេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៧៥ "ច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ៕

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០៛ ដែលអ្នកស្រី យី ឆេង បានបង់ជូស គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ្លឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ .

ហើយតំរូវឱ្យលោកចាន់ សានី សងប្រាក់ចំនួន១៩.០០០៛ នេះ ទៅអ្នកស្រីយី ឆេង វិញ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៤ ៗ